# ព្រះរាជក្រឹត្យ

នស/រកត/០៩១៨/៩៦២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៨៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រង និងបើកផ្តល់ប្រាក់ចំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈទីប្រឹក្សា នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ និងជំនួយការរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ចំនួន ០៥រូប ៖

១-ឯកឧត្តម **ជា សំណាង** ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម **ទូច សារ៉េត** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ**

៣-ឯកឧត្តម **ហេង សិទ្ធី** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឯកឧត្តម **ឯម ច័ន្ទវិចឡ្សន៍** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឯកឧត្តម **ខៀវ សុខឿន** ជាជំនួយការ មានឋានៈស្មើ **អគ្គនាយក** ។

BOYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៨

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

១៣៣.១៨០៩.៩៧៧

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសល្យបណ្ឌិត **ប៊ិន ឈិន**